ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេនា
លេខ: ៤៥៧/អ.ស.ន
ថ្ងៃ ០៥ ខែ ០៨ ឆ្នាំ ២០២១

សេចក្តីណែនាំ
ស្តីពី
ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនជម្រុញ ឬជូនលើក៣
ជូនយោធិន និងប្រពន្ធ ឬប្តី ក្នុងអគ្គនាយកដ្ឋានយោធសេនា និងអង្គភាពចំណុះ

អនុវត្តតាមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលកំពុងរីករាលដាលក្នុងសហគមន៍។

ដើម្បីធានាឲ្យដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនជម្រុញ ឬជូនលើក៣ ជូនយោធិន និងប្រពន្ធ ឬប្តី ក្នុងអគ្គនាយកដ្ឋានយោធសេនា និងអង្គភាពចំណុះ ដំណើរការដោយរលូន មានសណ្តាប់ធ្នាប់ល្អ និងអនុវត្តតាមវិធានការរបស់ក្រសួងសុខាភិបាល ៣ការពារ និង៣កុំ អគ្គនាយកដ្ឋានយោធសេនា សូមណែនាំដល់ប្រធានអង្គភាពចំណុះអគ្គនាយកដ្ឋានយោធសេនា ដូចខាងក្រោម៖

១- នាយកដ្ឋាននីមួយៗត្រូវចាត់តាំងនាយករង ០១រូប និងនាយបុគ្គលិក ទទួលខុសត្រូវសម្របសម្រួលការងារចាក់វ៉ាក់សាំងកូវីដ-១៩ ជូនលើក៣ ជូនយោធិន និងប្រពន្ធ ឬប្តី ក្នុងនាយកដ្ឋានរបស់ខ្លួននៅកន្លែងចាក់វ៉ាក់សាំង នៅអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ (កន្លែងធ្វើតេស "Rapid Test") ចំពោះពេលវេលាចាក់វ៉ាក់សាំងកូវីដ-១៩ អគ្គនាយកដ្ឋានយោធសេនា សូមបែងចែកដូចខាងក្រោម៖

- អគ្គនាយកដ្ឋានយោធសេនា នាយកដ្ឋានអប់រំ និងនាយកដ្ឋានសោធននិវត្តន៍ ដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនលើក៣ **នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១**។
- នាយកដ្ឋានព័ត៌មាន និងនាយកដ្ឋានកិច្ចការយោធាស៊ីវិល ដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនលើក៣ **នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១**។

២- មជ្ឈមណ្ឌលយោធិនពិការ ៣១៧ កោះស្លា និងមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ សម្តេចតេជោ ហ៊ុន សែន គូលេន ៣១៧ សៀមរាប ប្រធានអង្គភាពត្រូវរៀបចំទីកន្លែង និងពេទ្យរបស់អង្គភាពសម្រាប់ដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនលើក៣ ជូនយោធិន និងប្តី ឬប្រពន្ធ ក្នុងអង្គភាពរបស់ខ្លួន ចំពោះវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវចាក់ អគ្គនាយកដ្ឋានយោធសេនា នឹងសម្របសម្រួលជាមួយមន្ទីរពេទ្យព្រះកេតុមាលាដឹកជញ្ជូនទៅដល់អង្គភាព។

ទទួលបានសេចក្តីណែនាំនេះ ប្រធានអង្គភាពចំណុះអគ្គនាយកដ្ឋានយោធសេនាទាំងអស់ ត្រូវអនុវត្តក្នុងស្មារតីទទួលខុសត្រូវនិងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ១៣ កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០២១

អគ្គនាយក

នាយឧត្តមសេនីយ៍.ហាស សាវ៉ន